ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ៦ រោច ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃ ៤ ខែ កញ្ញា ឆ្នាំ ២០១៩*

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ)
## ស្តីពីការធ្វើអាទិភាវូបនីយកម្មក្នុងការជួសជុល និងសាងសង់ផ្លូវថ្នល់ ប្រព័ន្ធរំដោះទឹកភ្លៀង និងប្រព័ន្ធទឹកកខ្វក់ ក្នុងខេត្តព្រះសីហនុ

ដោយមានការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងឱកាសកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៩ កន្លងមក, នាព្រឹកថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៩, គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (គ.ស.ហ) ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន **គ.ស.ហ** បានរៀបចំកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាបន្ទាន់, ដើម្បីពិនិត្យ និងពិភាក្សាអំពី **"ការធ្វើអាទិភាវូបនីយកម្ម ក្នុងការជួសជុល និងសាងសង់ផ្លូវថ្នល់ក្នុងខេត្តព្រះសីហនុ"** ។ កិច្ចប្រជុំរៀបចំនៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបានការអញ្ជើញចូលរួមពីឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន, ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍, ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម **តឹករ៉េត សំរេច** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានក្រុងព្រះសីហនុ, ឯកឧត្តម **គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

បន្ថែមលើសេចក្តីសម្រេចរបស់កិច្ចប្រជុំ **គ.ស.ហ** កាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៩ និងដើម្បីឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែងនៅខេត្តព្រះសីហនុ, កិច្ចប្រជុំ **គ.ស.ហ** បន្ទាន់នេះបានពិនិត្យ និងពិភាក្សាលើការកំណត់ជាអាទិភាព រៀបចំក្របខណ្ឌ យន្តការនៃការអនុវត្តការងារឱ្យបានច្បាស់លាស់ចំពោះការជួសជុល កសាងផ្លូវក្នុងក្រុង ផ្លូវវាងក្រុង ប្រព័ន្ធរំដោះទឹកភ្លៀង និងប្រព័ន្ធទឹកកង្វក់ ក្នុងខេត្តព្រះសីហនុ ដើម្បីធានាបាននូវប្រសិទ្ធភាពការងារ សំណង់ប្រកបដោយគុណភាព ទាន់ពេលវេលា ក៏ដូចជា តម្លៃនៃថវិកា ។ ជាលទ្ធផល, អង្គប្រជុំ បានឯកភាពលើវិធាការ និងគោលការណ៍បន្ថែម ដូចខាងក្រោម÷

**ទី ១.** បន្តអនុវត្តន៍គោលការណ៍ដែលបានសម្រេចក្នុងកិច្ចប្រជុំ **គ.ស.ហ** កាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៩ កន្លងទៅ ចំពោះវិធានការការងារបន្ទាន់ និងអាទិភាព ក្នុងការស្តារអូរធម្មជាតិទាំង ៥ និងលូដែលមានស្រាប់ ដែលសព្វថ្ងៃកំពុងទទួលរងការរំលោភយកចំណីអូរ និងប្រឡាយ ដើម្បីបើកមុខទឹកហូរ និងដោះស្រាយជំនន់ ទឹកភ្លៀង ។

**ទី ២.** ក្នុងការស្តារ ជួសជុលផ្លូវក្នុងក្រុង ផ្លូវវាងក្រុង ការស្តាររៀបចំអូររំដោះទឹកភ្លៀង និងប្រព័ន្ធទឹកកង្វក់, កិច្ចប្រជុំ បានកំណត់អាទិភាព និងវាយតម្លៃពីទំហំនៃការស្តារ និងជួសជុលកំណាត់ផ្លូវទាំង ២២ ខ្សែ និងផ្លូវវាងក្រុង តាមបទដ្ឋានស្តង់ដា ដែលសិក្សាដោយគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដោយផ្សារភ្ជាប់ជាមួយនឹងគុណភាព, សោភណ្ឌភាព, សុវត្ថិភាព, តម្រូវការហិរញ្ញប្បទាន, តម្រូវការនៃការដោះស្រាយផលប៉ះពាល់ ក្នុងនោះ ត្រូវផ្តោតលើបច្ចេកទេសក្នុងការសាងសង់ ការត្រួតពិនិត្យគុណភាពសំណង់, ទំហំផ្លូវ, ការបង្កប់ប្រព័ន្ធខ្សែកាប, ទូរស័ព្ទ, បំពង់ទឹកស្អាត និងបណ្តាញទឹកកខ្វក់/ទឹកភ្លៀង ជាដើម ។

**ទី ៣.** ចំពោះប្រភពហិរញ្ញប្បទាន, បន្ថែមលើការឯកភាពជាគោលការណ៍របស់ប្រមុខរាជរដ្ឋាភិបាល ដែលអនុញ្ញាតឲ្យប្រើប្រាស់ថវិកាសន្សំរបស់រាជរដ្ឋាភិបាល ចំនួន ១០០ លានដុល្លារអាមេរិក, ត្រូវអនុវត្តគោលការណ៍ "**យកស្លឹកត្នោតខ្ទប់ស្ករត្នោត**" ដែលជាការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចំពោះការស្ថាបនា ជួសជុល កសាងផ្លូវក្នុងក្រុង ផ្លូវវាងក្រុង ប្រព័ន្ធរំដោះទឹកភ្លៀង និងប្រព័ន្ធទឹកកង្វក់ ក្នុងខេត្តព្រះសីហនុនេះ ។

ជាទីបញ្ចប់, អង្គប្រជុំ ក៏បានប្តេជ្ញាអនុវត្តតាមសេចក្តីសម្រេចដ៏ថ្លៃថ្លារបស់ប្រមុខរាជរដ្ឋាភិបាល ក៏ដូចជាស្មារតីអង្គប្រជុំ **គ.ស.ហ** និងបន្តផ្តល់កិច្ចសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តន៍កិច្ចការនេះ ។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងឲ្យអង្គប្រជុំទាំងមូល ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដែលតែងតែបានយកចិត្តទុកដាក់ខ្ពស់ ណែនាំចង្អុលបង្ហាញ និងដាក់ចេញវិធានការណ៍ជាបន្តបន្ទាប់ក្នុងការដោះស្រាយបញ្ហា សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា និយាយជារួម និងដោយឡែក ក្នុងការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តព្រះសីហនុនេះ ។